# ប្រើប្រាស់គណនីហិរញ្ញវត្ថុ របស់អ្នកដោយសុវត្ថិភាព

សូមជ្រើសរើស លេខកូដ
សំងាត់ដែរមានតែអ្នកទេទើបដឹង




ត្រូវតែប្រាដកថាលេខសំងាត់
របស់អ្នកគឺគ្មានអ្នកដឹង



មិនត្រូវអោយអ្នកណា
ដឹងលេខសម្ងាត់របស់អ្នក

ប្រយ័ត្នចំពោះការ
តេមកបន្លំនិងបោក




ប្រសិនបើអ្នកទទួលបានការហៅ
ទូរស័ព្ទសុំលេខកូដសម្ងាត់របស់អ្នក
សូមឈប់និយាយទោះបីជាពួកគេនិយាយ
ថាពួកគេមកពីធនាគាររបស់អ្នកក៏ដោយ

"ខ្ញុំនឹងមិនចែករំលែកលេខកូ
ដសម្ងាត់របស់ខ្ញុំជាមួយនរ
ណាម្នាក់នោះទេ
ព្រោះដើម្បីរក្សាគណនី
របស់ខ្ញុំឱ្យមានសុវត្ថិភាព ។"



RISE | Center for Inclusive Growth

# សេវាហិរញ្ញវត្ថុគឺសំរាប់អ្នក

## គណនីឌីជីថលគឺ...

### មានសុវត្ថិភាព និងងាយស្រួល

- អ្នកអាចចូលប្រើគណនីរបស់អ្នកពីទូរស័ព្ទរបស់អ្នក
- អ្នកអាចប្រើកាតធនាគារ
- អ្នកអាចដកប្រាក់របស់អ្នកគ្រប់ពេល
- អ្នកអាចរក្សាទុកប្រាក់របស់អ្នកនៅក្នុងធនាគារ

### ងាយស្រួល

- បង់លុយទៅអ្នកលក់
- ផ្ញើរប្រាក់
- បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ
- បង់វិក័យប័ត្រ

- នៅលើគណនីរបស់អ្នកអ្នកអាចតាមដានប្រាក់ចំណូលនិងការចំណាយរបស់អ្នកជារៀងរាល់ខែហើយអាចគ្រប់គ្រងលើប្រាក់ឈ្នួលរបស់អ្នក
- ត្រូវប្រាកដថាអ្នកដឹងថាថ្លៃសេវានិងការកំណត់គណនីមានប៉ុន្មាន
- ប្រសិនបើអ្នកមានបញ្ហាសូមទាក់ទងអ្នកគ្រប់គ្រងរោងចក្ររបស់អ្នកឬទូរស័ព្ទទៅអ្នកផ្តល់សេវាកម្មហិរញ្ញវត្ថុរបស់អ្នក

"មានគណនីឌីជីថលជារបស់ខ្លួនឯង ជួយអោយខ្ញុំមានភាពងាយស្រួលក្នុងការគ្រប់គ្រងប្រាក់ចំណូលនិងសន្សំ។ វាក៏ផ្តល់ភាពងាយស្រួលក្នុងការផ្ញើប្រាក់ទៅផ្ទះផងដែរ។"



# ផែនការហិរញ្ញវត្ថុ

## តើគោលបំណងហិរញ្ញវត្ថុរបស់អ្នកជាអ្វី?




### គន្លឹះសំខាន់ៗ

ពិភាក្សានិងឯកភាពលើគោលដៅរបស់អ្នកនិងចំនួនប្រាក់ដែលត្រូវសន្សំជាមួយគ្រួសារអ្នក

ចាប់ផ្តើមសន្សំដើម្បីឆ្ពោះទៅគោលដៅរបស់អ្នកក្នុងគណនីឌីជីថលរបស់អ្នកហើយពិនិត្យមើលសមតុល្យដើម្បីតាមដានការចំណាយរបស់អ្នក

"គោលដៅរបស់ខ្ញុំគឺចង់អោយកូនស្រីខ្ញុំបានរៀនមហាវិទ្យាល័យ។ ខ្ញុំក៏ចង់ទិញដីសំរាប់ធ្វើកសិកម្មមួយចំនួននៅក្នុងភូមិខ្ញុំផងដែរ។ ខ្ញុំបានរៀបចំផែនការជាមួយគ្រួសារខ្ញុំថាតើយើងត្រូវសន្សំប៉ុន្មានក្នុងមួយខែដើម្បីឈានដល់គោលដៅរបស់យើង។"



RISE | Center for Inclusive Growth

# ការរៀបគម្រោងថវិកា

| | របស់របរ | ចំនួន |
|---|---|---|
| ចំណូល | ប្រាក់ឈ្នួល<br>ប្រាក់ឈ្នួលរបស់អ្នក<br>ប្រាក់ឈ្នួលរបស់ដៃគូអ្នក<br>ចំណូលផ្សេងៗទៀត<br>ចំណូលពីរកសិកម្ម | |
| ការចំណាយ | ចាំបាច់<br>អាហារសុខភាព<br>ថ្លៃឈ្នួលផ្ទះ<br>ចំណាយ<br>ថ្នាំពេទ្យ<br>ថ្លៃសាលា<br>មិនចាំបាច់<br>អាហារសំរន់<br>ខោអាវថ្មី | |
| សមតុល្យ | ចំណូល ដក ចំណាយ | |

ប្រាក់សល់ = ការសន្សំ

## គន្លឹះសំខាន់ៗ

បង្កើតគម្រោងថវិកាជាមួយគ្រួសារអ្នក។ ផ្តោតលើការចំណាយចាំបាច់និងកាត់បន្ថយការចំណាយដែលមិនចាំបាច់។

រក្សាទុកប្រាក់សន្សំក្នុងគណនីហិរញ្ញវត្ថុរបស់អ្នក។

"ខ្ញុំបានបង្កើតគម្រោងថវិកាជាមួយគ្រួសារខ្ញុំ ពួកយើងអាចកាត់បន្ថយការចំណាយលើអាហារសម្រន់ដែរមិនល្អចំពោះសុខភាព និងសន្សំសម្រាប់ថ្លៃមហាវិទ្យាល័យនាពេលអនាគតរបស់កូនស្រី។"



ធ្វើអតិភាពការចំណាយចាំបាច់



កាត់បន្ថយការចំណាយមិនចាំបាច់



RISE
Center for Inclusive Growth

# អ្នកទាំងអស់គ្នាអាចសន្សំបាន តោះចាប់ផ្តើមពីថ្ងៃនេះ

## ហេតុអ្វីអ្នកត្រូវសន្សំ



- ដើម្បីសម្រេចគោលដៅរបស់អ្នក
- ក្នុងករណីមានអាសន្ន

## វិធីសន្សំ



- សម្រេចចិត្តថាអ្នកត្រូវសន្សំចំនួនប៉ុន្មាន
- គួរតែដកប្រាក់ចំនួនដែលអ្នកត្រូវការបានហើយ ហើយរក្សាប្រាក់ដែលនៅសល់នៅក្នុងគណនីរបស់អ្នក

## ទុកថវិការអោយមានសុវត្ថិភាព



- បើកនិងប្រើប្រាស់គណនីសន្សំ

"ខ្ញុំសន្សំ២៥ដុល្លារក្នុងមួយខែនៅក្នុងគណនីធនាគាររបស់ខ្ញុំ សំរាប់ឆ្ពោះទៅរកក្តីសុបិនអោយកូនស្រីបានរៀនមហាវិទ្យាល័យ។"



## ទទួលខុសត្រូវនូវប្រាក់កម្ចី

- វាជាការល្អប្រសើរក្នុងការសន្សំសំរាប់ការចំណាយធំ ជាជាងការយកប្រាក់កម្ចី
- ប្រសិនបើអ្នកពិតជាត្រូវការប្រាក់កម្ចី អ្នកគួរតែយកពីប្រភពច្បាស់លាស់ដូចជាធនាគារ
- ប្រសិនបើអ្នកខកខានការទូទាត់ប្រាក់កម្ចី វានឹងធ្វើឱ្យអ្នកចំណាយកាន់តែច្រើន

RISE | Center for Inclusive Growth

# ជជែកអំពី ហិរញ្ញវត្ថុ ជាមួយគ្រួសាររបស់អ្នក

ក្រុមគ្រួសារដែលពិភាក្សាអំពីហិរញ្ញវត្ថុជាមួយគ្នាតែងតែអាចសំរេចតាមគោលដៅហិរញ្ញវត្ថុរបស់ពួកគេនិងមានទំនាក់ទំនងចុះសម្រុងគ្នា

## ព័ត៌មានជំនួយ ការទំនាក់ទំនង

- ទទួលស្គាល់ការយល់ឃើញរបស់ដៃគូរ
- បញ្ជាក់ជំហររបស់អ្នកដោយភាពជឿជាក់
- សម្របសម្រួលដើម្បីរកដំណោះស្រាយរួម
- ស្តាប់ដៃគូរបស់អ្នក
- ផ្តល់អាកិប្បកិរិយាល្អពេលជជែកគ្នា
- កុំនាំបញ្ហាផ្សេងៗមកក្នុងការសន្ទនា




ប្រសិនបើអ្នកប្រឈមមុខនិងជម្លោះរឺអំពើហឹង្សានៅផ្ទះសូមទូរស័ព្ទទៅលេខ ១១៧ សំរាប់ជំនួយពីប៉ូលីសរឺក៏ទូរស័ព្ទទៅលេខ ១២៨០ សំរាប់អំពើហឹង្សាប្រឆាំងនឹងស្ត្រីនិងកុមារ